ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ. ធ៧-០១៨-០០៤ ប្រ.ក.ព.ធ

ថ្ងៃ អង្គារ ៥ កើត ខែទុតិយាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ២០១៨

## សេចក្ដីប្រកាសព័ត៌មាន
## ស្ដីពី ការហាមឃាត់ទទួលយកអត្តសញ្ញាណបណ្ណ ឬ សៀវភៅគ្រួសារ និងសៀវភៅស្នាក់នៅ សម្រាប់ការធានាលើការផ្ដល់ឥណទាន

ធនាគារជាតិនៃកម្ពុជាមានកិត្តិយស សូមជម្រាបជូនសាធារណជន មេត្តាជ្រាបថា កន្លងមក ធនាគារជាតិនៃកម្ពុជាបានជូនដំណឹងអំពីការហាមឃាត់ទទួលយកអត្តសញ្ញាណបណ្ណឬសៀវភៅគ្រួសារ និងសៀវភៅស្នាក់នៅ សម្រាប់ការធានាលើការផ្ដល់ឥណទាន ជាបន្តបន្ទាប់ ចាប់ពីខែមីនា ឆ្នាំ២០១៦។ ប៉ុន្តែ ធនាគារជាតិនៃកម្ពុជា សង្កេតឃើញថា គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងគ្រឹះស្ថានឥណទានជនបទមួយចំនួននៅតែអនុវត្តមិនទាន់បានពេញលេញ តាមសេចក្ដីជូនដំណឹងខាងលើ។

ហេតុដូចនេះ ធនាគារជាតិនៃកម្ពុជា សូមក្រើនរំលឹកជាថ្មីម្ដងទៀតថា គ្រឹះស្ថានទាំងអស់ត្រូវយកចិត្តទុកដាក់អនុវត្តតាមខ្លឹមសារនៃសេចក្ដីជូនដំណឹងរបស់ធនាគារជាតិនៃកម្ពុជា លេខធ៧.០១៦.២១០. សជណ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៦ ឲ្យបានពេញលេញ និងម៉ឺងម៉ាត់បំផុត។ ក្នុងករណីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងគ្រឹះស្ថានឥណទានជនបទណា នៅតែបន្តសកម្មភាព និងមិនយកចិត្តទុកដាក់អនុវត្តតាមសេចក្ដីជូនដំណឹងនេះ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងគ្រឹះស្ថានឥណទានជនបទនោះនឹងត្រូវទទួលរងទណ្ឌកម្មខាងវិន័យធ្ងន់ធ្ងររហូតដល់ការដកហូតអាជ្ញាប័ណ្ណអាជីវកម្មស្របតាមមាត្រា ៥២ និង ៥៦ នៃច្បាប់ស្ដីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ជាធរមាន។

អាស្រ័យដូចបានជម្រាបជូនខាងលើនេះ សូមសាធារណជនមេត្តាជ្រាបជាពត៌មាន និងស្នើសាធារណជនមានការប្រុងប្រយ័ត្ន និងចៀសវាងការប្រើប្រាស់អត្តសញ្ញាណបណ្ណឬសៀវភៅគ្រួសារ និងសៀវភៅស្នាក់នៅ សម្រាប់ការធានាលើការខ្ចីឥណទាន។

ទំនាក់ទំនង៖
អគ្គនាយកដ្ឋានត្រួតពិនិត្យ
ទូរស័ព្ទ៖ (៨៥៥) ៨៥ ៦០០ ០០២